# ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០

## សេចក្តីសំរេចលេខ ៣០ សសរ

## ស្តីពីការបង្កើតគណកម្មការទទួលរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី កសិកម្មនិង ព្រៃឈើអាស៊ាន និង កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី កសិកម្ម និង ព្រៃឈើអាស៊ាន

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ : បង្កើតគណៈកម្មការទទួលការរៀបចំកិច្ចប្រជុំ ៖

ក-កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និង ព្រៃឈើអាស៊ានលើកទី ២២ ដែលភាសាអង់គ្លេស ហៅថា The twenty second Meeting of the ASEAN Ministers on Agriculture and Forestry ហៅកាត់ថា AMAF ខែ តុលា ឆ្នាំ ២០០០ នៅរាជធានីភ្នំពេញ ។

ខ-កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីកសិកម្ម និង ព្រៃឈើអាស៊ានលើកទី ២២ ដែលភាសាអង់គ្លេស ហៅថា The Senior Officials Meeting Of the 22 nd Meeting of the ASEAN Ministers on Agiculture and Forestry ហៅកាត់ថា SOM- AMAF ខែ តុលា ឆ្នាំ ២០០០ នៅរាជធានីភ្នំពេញ ។

គ-កិច្ចប្រជុំពិសេសថ្នាក់ឧត្តមមន្ត្រីកសិកម្ម និង ព្រៃឈើអាស៊ានលើកទី ២២ ដែលភាសាអង់គ្លេស ហៅថា The Special Senior Officials Meeting of the 22 nd Meeting of ASEAN Ministers on Agriculture and Forestry ហៅថាកាត់ថា Special SOM AMAF ខែ មេសា ឆ្នាំ ២០០១ ។

ប្រការ ២ : គណៈកម្មការទទួលរៀបចំកិច្ចប្រជុំនេះ មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១ -ឯកឧត្តម | ចៀម សំអឿន | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | ប្រធាន |
| ២ -លោកជំទាវ | ស៊ុន សារឿន | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣ | -ឯកឧត្តម | អ៊ិត ឈន | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៤ | -ឯកឧត្តម | ទិន ឃិន | ប្រធានគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ និងអន្តរជាតិ | សមាជិក |
| ៥ | -ឯកឧត្តម | យូ ស៊ុនឡុង | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៦ | -ឯកឧត្តម | អ៊ិន សុជាតិ | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧ | -ឯកឧត្តម | អ៊ី លន់ | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៨ | -ឯកឧត្តម | សូ ម៉ារ៉ា | អគ្គនាយកក្រសួងទេសចរណ៍ | សមាជិក |
| ៩ | -ឯកឧត្តម | នូ លីឡុ | អគ្គលេខាធិការង OBSES | សមាជិក |

ប្រការ ៣ : គណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានលេខាធិការដ្ឋានរបស់ខ្លួន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទជាសេនាធិការ ។

ប្រការ ៤ : គណៈកម្មការទទួលរៀបចំកិច្ចប្រជុំនេះ មានភារកិច្ចដូចតទៅ ៖

ក-រៀបចំកម្មវិធី នៃកិច្ចប្រជុំនិងពិធីការអោយបានសមស្រប ។

ខ-រៀបចំគំរោងថវិកាចំណាយក្នុងការរៀបចំកិច្ចប្រជុំនេះ រួចលើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល ។

គ-សំរបសំរួលរៀបចំការពារសន្តិសុខដល់រដ្ឋមន្ត្រី និង ឧត្តមមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានអោយមានសុវត្ថិភាពល្អ ។

ឃ-ទទួលបន្ទុករៀបចំតាត់តែងសំដែងសិល្បៈ របាំប្រពៃណីជូនគណៈប្រតិភូទស្សនាក្នុងពេលរាត្រីភោជនាហារ ព្រមទាំងរបាំជាតិ និងភាគអន្តរជាតិជាបងប្អូនក្នុងប្រទេសអាស៊ាន ។

ង-ជួយសំរបសំរួល និង តាត់តែងលើការធ្វើដំណើរទស្សនាចរណ៍ដល់ប្រតិភូក្រោយកិច្ចប្រជុំចប់តាមកម្មវិធីដែលបានគ្រោងទុក ។

ច-ជួយសំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយកិច្ចប្រជុំនេះ ។

ប្រការ ៥ : សមាជិកនៃគណៈកម្មការបំពេញការងារស្របតាមការចាត់តាំងរបស់ប្រធាន ។

ប្រការ ៦ : គណៈកម្មការមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង និង ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារផ្សេងៗ ។

ប្រការ ៧ : គណៈកម្មការ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗទៀត តាមការចាំបាច់ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីរដ្ឋលេខាធិការ នៃ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០

## សេចក្តីសំរេចលេខ ៣១ សសរ
## ស្តីពីការបង្កើតគណៈកម្មការចំរុះកម្ពុជា –ឥណ្ឌា

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការចំរុះកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការកម្ពុជា- ឥណ្ឌា ដែលមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីឬរដ្ឋលេខាធិការ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | តំណាងក្រសួងការពារជាតិ | សមាជិក |
| ៤- | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧- | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨- | តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៩- | តំណាងក្រសួងទេសចរណ៍ | សមាជិក |